USAID FROM THE AMERICAN PEOPLE

RECOFTC THE CENTER FOR PEOPLE AND FORESTS

# The Grassroots Equity Newsletter



ធ្វើការជាមួយពលរដ្ឋនៅមូលដ្ឋានក្នុងតំបន់មេគង្គ ដើម្បីលើកកម្ពស់កិច្ចផ្តួចផ្តើមស្តីពីសមធម៌ក្នុងការកាត់បន្ថយការប្រែប្រួលអាកាសធាតុឲ្យមានប្រសិទ្ធភាព

• លេខ ៥ • ខែ កក្កដា ឆ្នាំ ២០១៥

## អំពីកម្មវិធី GREEN Mekong

ព្រឹត្តិបត្រព័ត៌មាននេះត្រូវបានផលិតឡើងដោយកម្មវិធីសមធម៌ និងការពង្រឹងបណ្តាញនៅមូលដ្ឋានក្នុងតំបន់មេគង្គ (កម្មវិធី GREEN Mekong) ដែលទទួលមូលនិធីគាំទ្រពី USAID និងមានគោលដៅពង្រឹងសមត្ថភាពរបស់អ្នកកសាងគោលនយោបាយ និងអ្នកពាក់ព័ន្ធនានានៅថ្នាក់មូលដ្ឋានក្នុងតំបន់មេគង្គក្រោម ដើម្បីលើកកំពស់សមធម៌ក្នុងគោលនយោបាយ និងការអនុវត្ត ដែលកាត់បន្ថយការប្រែប្រួលអាកាសធាតុដោយផ្អែកលើព្រៃឈើ ។

កម្មវិធីនេះបានផ្អែកលើប្រការដែលថា ភាពបរាជ័យជាច្រើនក្នុងកិច្ចការពារព្រៃឈើ បានកើតឡើងដោយសារការមិនលើកយកមកពិចារណានូវតម្រូវការ ការចង់បានចំណេះដឹង និងការចូលរួមរបស់ប្រជាជនក្នុងមូលដ្ឋាន នៅក្នុងដំណើរការធ្វើសេចក្តីសម្រេច ។ នៅក្នុងតំបន់មេគង្គក្រោមដែលប្រជាជនជាច្រើនលាននាក់នៅតែពឹងផ្អែកលើធនធានព្រៃឈើ គោលនយោបាយ និងយុទ្ធសាស្ត្រដែលរៀបចំឡើង ដើម្បីការពារព្រៃឈើ កាត់បន្ថយការបំភាយកាបូន និងកាត់បន្ថយ ការប្រែប្រួលអាកាសធាតុ នឹងទទួលជោគជ័យតែក្នុងករណីដែលមានការចូលរួមពីសហគមន៍មូលដ្ឋានតែប៉ុណ្ណោះ ។

កម្មវិធី GREEN Mekong បានទទួលការគាំទ្រមូលនិធិពីបេសកកម្មអភិវឌ្ឍន៍ប្រចាំតំបន់អាស៊ី (RDMA) នៃទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ(USAID) និងអនុវត្តដោយរ៉ិខូហ្វ-មជ្ឈមណ្ឌលសម្រាប់មនុស្សនិងព្រៃឈើ (RECOFTC – The Center for People and Forests) ។

## នៅក្នុងលេខនេះ


- ក្រុមអ្នកសិក្សាថ្នាក់តំបន់ ៖ វិធីសាស្ត្រមួយដែលផ្តល់ឥទ្ធិពល
- ការសង្កេតល្បិតល្អន់ជាមួយក្រុមអ្នកសិក្សាថ្នាក់តំបន់
- តំណាងមកពីអង្គការសង្គមស៊ីវិល ជួបប្រជុំនៅទីក្រុងបាងកក ដើម្បីពង្រឹងបន្ថែមជំនាញសម្របសម្រួលរបស់ខ្លួន
- បច្ចុប្បន្នភាពពីមូលនិធិ GREEN Mekong
- ឯកសារនានាអំពីសមធម៌
- ទស្សនៈយេនឌ័រ








# ក្រុមអ្នកសិក្សាថ្នាក់តំបន់៖ វិធីសាស្ត្រមួយដែលផ្តល់ឥទ្ធិពល

“ប្រសិនបើគ្មានព្រៃឈើទេ ប្រទេសឡាវពុំដឹងក្លាយជាយ៉ាងណា។ ខ្ញុំដឹងថាសហគមន៍ពឹងផ្អែកលើព្រៃឈើរបស់ពួកគេ ជាប្រចាំថ្ងៃសម្រាប់ចិញ្ចឹមគ្រួសារ និងទ្រទ្រង់របរចិញ្ចឹមជីវិតរបស់ពួកគេ។ ប្រទេសទាំងមូល និងសូម្បីតែតំបន់នេះ ក៏ទទួលផលពីព្រៃឈើដែលមានស្ថានភាពល្អរយៈពេលវែង និងពឹងផ្អែកលើព្រៃឈើទាំងនេះផងដែរ។” នេះជាអ្វីដែលលោកប៊ុនចាន់ ឡាតាណាវង្គត អនុប្រធានផ្នែកព្រៃឈើនៅខេត្តលួងប្រាបាង នៃប្រទេសឡាវ រៀបរាប់ពីសារៈសំខាន់នៃការការពារព្រៃឈើនៅក្នុងមហាតំបន់មេគង្គ។ បើគ្មានព្រៃឈើទេនោះ ប្រជាជនជាច្រើនលាននាក់ នឹងបាត់បង់លទ្ធភាពទទួលបានស្បៀងអាហាររបស់ខ្លួន។



អ្នកជំនាញមួយរូបបង្ហាញអំពីបញ្ហាសមធម៌នៅក្នុងមូលដ្ឋាន ដល់សមាជិកក្រុមអ្នកសិក្សាថ្នាក់តំបន់ នៅក្រុងសៀមរាប ព្រះរាជាណាចក្រកម្ពុជា។

សហគមន៍នានាដែលស្ថិតនៅក្នុង និង ជិតព្រៃឈើ ជីវត្តនាទីសំខាន់ក្នុងការថែរក្សាព្រៃឈើទាំងនេះ ។ ប្រជាជនទាំងនេះស្គាល់ព្រៃបានច្បាស់ ជាងគេ ប៉ុន្តែជាញឹកញាប់បំផុត ពួក គេមិនត្រូវបានអនុញ្ញាតឲ្យពាក់ព័ន្ធនៅក្នុងដំណើរនៃការធ្វើសេចក្តីសម្រេចឡើយ ដែលធ្វើឲ្យពួកគេងាយរងគ្រោះដោយសារតគោលនយោបាយ និងការអនុវត្តពុំត្រឹមត្រូវ និង គ្មានសមធម៌នៅក្នុងការគ្រប់គ្រងព្រៃឈើ ដែលជាហេតុធ្វើឲ្យពួកគេស្ថិតក្នុងហានិភ័យ។ ការត្រឹមតែបានដឹងពីបញ្ហានានៅពុំទាន់គ្រប់គ្រាន់ឡើយ ដើម្បីអាចការពារព្រៃឈើ និងប្រជាជនដែលពឹងផ្អែកលើព្រៃឈើបាន។ រដ្ឋាភិបាលត្រូវធ្វើការងារជាមួយសហគមន៍ទាំងនេះ។

តាមរយៈសិក្ខាសាលាជាបន្តបន្ទាប់ចំនួនបួនលើក ក្រុមអ្នកសិក្សាថ្នាក់តំបន់កំពុងធ្វើឲ្យប្រាកដថា ពួកគេអាចឆ្លើយតបនឹងបញ្ហាពិតប្រាកដ ដែលសមាជិកក្រុមសិក្សាថ្នាក់តំបន់បានរកឃើញតាមរយៈវគ្គបណ្តុះបណ្តាលទាំងនេះ។ លោក ឡាតាណាវង្គត មានបទពិសោធន៍ជាក់ស្តែងពីការរៀនសូត្រផ្ទាល់ខ្លួនអំពីបញ្ហានេះ៖ “តាមរយៈការចូលរួមនៅក្នុងសិក្ខាសាលាទាំងនេះ យើងបានរៀនអំពីបែបបទនៃការជជែកពិភាក្សាជាមួយសហគមន៍។ បន្ទាប់មក នៅពេលយើងត្រឡប់មកមូលដ្ឋានរបស់យើងវិញ យើងជួបជាមួយប្រជាជន និង បានប្រមូលព័ត៌មានអំពីបញ្ហានានាដែលមានសារៈសំខាន់ចំពោះអ្នកទាំងនោះ។ ប៉ុន្តែយើងមិនត្រឹមតែជួបជាមួយប្រជាជនទាំងនេះប៉ុណ្ណោះទេ យើងក៏យល់ផងដែរពីការធ្វើយ៉ាងណាដើម្បីឲ្យមានសមធម៌នៅក្នុងវិធីសាស្ត្ររបស់យើង ដោយជួបជជែកជាមួយស្ត្រី និងសមាជិកដទៃទៀតក្នុងសហគមន៍ដែលមានសម្លេងតិចតួច”។

គោលដៅរបស់ក្រុមអ្នកសិក្សាថ្នាក់តំបន់ គឺគូសបញ្ជាក់ពីសារៈសំខាន់នៃសមធម៌នៅក្នុងដំណើរការធ្វើសេចក្តីសម្រេច ដោយគិតតាំងពីពេលចាប់ផ្តើម រហូតដល់ចុងបញ្ចប់ ហើយការបណ្តុះបណ្តាលបន្ថែមអាចធ្វើឲ្យសម្រេចបាននូវគោលដៅនេះ។ លទ្ធផលនេះ គឺជាការផ្លាស់ប្តូរដ៏សំខាន់មួយនៃឥរិយាបថ ឆ្ពោះទៅរកអភិបាលកិច្ចព្រៃឈើ និងការកសាងគោលនយោបាយនៅថ្នាក់ខេត្ត។ ឥឡូវនេះ មន្ត្រីព្រៃឈើយល់បានប្រសើរជាងមុនពីរបៀបធ្វើយ៉ាងណាឲ្យសមាជិកសហគមន៍បានចូលរួម និងរបៀបប្រាស្រ័យទាក់ទងជាមួយអ្នកទាំងនោះ ដោយធ្វើឲ្យការចូលរួមរបស់ពួកគេកាន់តែមានឥទ្ធិពលខ្លាំងឡើងៗ និងអាចការពារព្រៃឈើ ដែលនេះជាគោលបំណងរួមដ៏សំខាន់សម្រាប់មនុស្សគ្រប់រូប។

យោបល់របស់លោកឡាតាណាវង្គត ឆ្លុះបញ្ចាំងពីការយល់ដឹងស៊ីជម្រៅបែបនេះអំពីសារៈសំខាន់នៃសមធម៌ និងថាតើសមាជិកក្រុមអ្នកសិក្សាថ្នាក់តំបន់មានការប្តេជ្ញាចិត្តកម្រិតណា ក្នុងការជម្រុញសមធម៌៖ “ដើម្បីពង្រឹងការចូលរួម គឺត្រូវធានាការពារសិទ្ធិរបស់ពួកគេចំពោះធនធានធម្មជាតិ។ ហើយនៅពេលដែលយើងបានធានាសិទ្ធិរបស់ពួកគេហើយនោះ សមធម៌នឹងកើតមានឡើង។ ជាមួយសមធម៌ និងសិទ្ធិ ប្រជាជននឹងបានទទួលផល និងធានាដល់ការពារធនធានបានផងដែរ។

# ការសង្កេតល្អិតល្អន់ជាមួយក្រុមអ្នកសិក្សាថ្នាក់តំបន់




” ថ្មីៗនេះ កម្មវិធី GREEN Mekong បានរួមបញ្ចូលគ្នានូវសកម្មភាពរបស់ក្រុមអ្នកសិក្សាថ្នាក់តំបន់នៅក្នុងតំបន់មេគង្គ។ វីដេអូនេះបង្ហាញពីវិធីសាស្ត្ររបស់យើងក្នុងការចាត់ទុកការអភិវឌ្ឍសមត្ថភាពមន្ត្រីរដ្ឋបាលព្រៃឈើនៅថ្នាក់ខេត្ត និងមូលដ្ឋាន ជាអាទិភាពក្នុងគោលដៅកែលម្អជាយុទ្ធសាស្ត្រនូវសមធម៌សង្គមក្នុងអភិបាលកិច្ចព្រៃឈើ។ ជាមួយការប៉ុនប៉ងបំពេញភាពខ្វះចន្លោះរវាងសហគមន៍នានា និងរដ្ឋាភិបាល មន្ត្រីរដ្ឋបាលព្រៃឈើនៅថ្នាក់ខេត្ត និងមូលដ្ឋាន ក្នុងបណ្តាប្រទេសនៃតំបន់មេគង្គក្រោម បានទទួលការបណ្តុះបណ្តាល និងការគាំទ្រ ដើម្បីកែលម្អ និងអនុវត្តវិធីសាស្ត្រ ដែលកាន់តែមានសមធម៌ នៅក្នុងគោលនយោបាយ និងការអនុវត្តខាងអភិបាលកិច្ចព្រៃឈើ។



វីដេអូនេះមាននៅទីនេះ៖ http://www.recoftc.org/project/green-mekong/videos/green-mekong-regional-learning-group

ក្រុមអ្នកសិក្សាថ្នាក់តំបន់ស្តីពីអភិបាលកិច្ចដោយសមធម៌ បានបន្តដំណើរការរបស់ខ្លួននៅក្រុងសៀមរាប នៃព្រះរាជាណាចក្រកម្ពុជា កាលពីថ្ងៃទី ២-៧ ខែមីនា ឆ្នាំ ២០១៥។ មន្ត្រីជាន់ខ្ពស់ក្នុងវិស័យព្រៃឈើនៅថ្នាក់ខេត្តចំនួន ១៩ រូប មកពីក្នុងតំបន់នេះបានជួបប្រជុំជាថ្មីម្តងទៀតនៅក្នុងសិក្ខាសាលាក្រុមអ្នកសិក្សារៀនសូត្រលើកទី ៣។ មន្ត្រីទាំងនេះដែលទាំងអស់គ្នាក៏ជាសិក្ខាកាមនៅក្នុងសិក្ខាសាលានៃក្រុមអ្នកសិក្សារៀនសូត្រថ្នាក់តំបន់ពីរលើកកន្លងមកហើយនោះ បានអភិវឌ្ឍន៍សមត្ថភាពរបស់ពួកគេជាបន្ថែមទៀត ដើម្បីវាយតម្លៃ និងជម្រុញសមធម៌នៅថ្នាក់មូលដ្ឋាន និងការចូលរួមនៅថ្នាក់មូលដ្ឋាន ជាមួយ សហគមន៍នានា ដែលពួកគេធ្វើការជាមួយ។ ជាមួយព័ត៌មានដែលប្រមូលបានពីសហគមន៍ទាំងនេះនារវាងសិក្ខាសាលាទាំងនេះ សិក្ខាកាមទាំងនេះបានរៀនចំផែនការសកម្មភាព របស់ខ្លួនដើម្បីកែលម្អសមធម៌នៅក្នុងបរិបទការងាររបស់ពួកគេរៀងៗខ្លួន។ សិក្ខាសាលានេះដែលមានរយៈពេលប្រាំមួយថ្ងៃ ក៏មានរួមបញ្ចូលទស្សនកិច្ចនៅតាមទីតាំងក្នុងមូលដ្ឋានផងដែរ ដែលនៅទីនោះ សិក្ខាកាមបានឃើញផ្ទាល់ភ្នែកនូវរបៀបដែលសហគមន៍ព្រៃឈើធ្វើការជាមួយក្រុមអ្នកពាក់ព័ន្ធ ខុសៗគ្នាជាច្រើនស្ថាប័ន ដោយធ្វើសហប្រតិបត្តិការដើម្បីការពារព្រៃឈើពីការគំរាមកំហែងនានា។ ជាមួយការយល់ដឹងរបស់ខ្លួនអំពីសមធម៌ សិក្ខាកាមក៏បានផ្តល់យោបល់តបទៅសហគមន៍វិញផងដែរ ដើម្បីលើកទឹកចិត្តឲ្យមានការកែលម្អដំណើរការគ្រប់គ្រងព្រៃឈើរបស់ពួកគេ។

សិក្ខាសាលាចុងក្រោយនៃក្រុមអ្នកសិក្សាថ្នាក់តំបន់ នឹងធ្វើឡើងនៅក្នុងប្រទេសឡាវ នៅចុងខែកក្កដា។ សិក្ខាសាលានោះនឹងផ្តល់ឲ្យសមាជិកក្រុមអ្នកសិក្សាថ្នាក់តំបន់ នូវឱកាសដើម្បីបង្ហាញជូនដល់សហការីរបស់ខ្លួននូវផលិតផលចំណេះដឹងរបស់ខ្លួន ដែលបង្ហាញពីបរិបទ និងបញ្ហាសមធម៌ដែលពួកគេបានកំណត់ឃើញ។ សិក្ខាកាមក៏នឹងរៀបចំផែនការផ្សព្វផ្សាយផងដែរ ដើម្បីចែករំលែកការសិក្សាសំខាន់ៗពីដំណើរការរបស់ក្រុមអ្នកសិក្សាថ្នាក់តំបន់មុននឹង វិលត្រឡប់ទៅប្រទេសរៀងៗខ្លួនវិញ។



# តំណាងមកពីក្រុមអង្គការសង្គមស៊ីវិល ជួបប្រជុំដើម្បីពង្រឹងបន្ថែមជំនាញសម្របសម្រួលរបស់ខ្លួន

ជាផ្នែកមួយនៃផែនការអភិវឌ្ឍន៍សមត្ថភាព និងការចូលរួមរបស់ខ្លួនរយៈពេលពីរ ឆ្នាំនៅក្រោមកម្មវិធី GREEN Mekong សម្រាប់អង្គការសង្គមស៊ីវិល នៅទូទាំងតំបន់ទន្លេមេគង្គក្រោម USAID និង RECOFTC បានអញ្ជើញតំណាងមកពីអង្គការចំនួន ២០ ដើម្បីជួបប្រជុំនៅទីក្រុងបាងកក នៅក្នុងសិក្ខាសាលាបណ្តុះបណ្តាលលើកទីបី នាថ្ងៃទី ២៣-២៧ ខែមីនា ឆ្នាំ ២០១៥។

តំណាងមកពីអង្គការសង្គមស៊ីវិលជាដៃគូក្នុងកម្មវិធី GREEN Mekong ដែលធ្វើការជាមួយសហគមន៍ព្រៃឈើនៅក្នុងតំបន់មេគង្គក្រោម បានចូលរួមនៅក្នុងសិក្ខាសាលាបណ្តុះបណ្តាលជាបន្តបន្ទាប់ ដើម្បីពង្រឹងតួនាទីរបស់ខ្លួនជាអ្នកសម្របសម្រួលនៅមូលដ្ឋាន។ ជាលទ្ធផល ពួកគេពង្រឹងការចូលរួមប្រកបដោយអត្ថន័យ និងសមធម៌ជាងមុន ជាមួយក្រុមអ្នកដែលមានចំណាប់អារម្មណ៍ខុសៗគ្នា ក៏ដូចជា ការបង្កើតលក្ខខណ្ឌប្រសើរជាងមុនសម្រាប់អ្នកពាក់ព័ន្ធនានានៅក្នុងមូលដ្ឋាន ដើម្បីសំដែងយោបល់ និងធ្វើសេចក្តីសម្រេចដើម្បីខ្លួនឯងអំពីកិច្ចផុតចុងផុតីមព្រៃឈើនិងការប្រែប្រួលអាកាសធាតុដែលមានឥទ្ធិពលមកលើពួកគេផងដែរ។



សិក្ខាកាមនៅក្នុងកិច្ចប្រជុំនៃអង្គការសង្គមស៊ីវិល កត់ត្រាវគ្គ បណ្តុះបណ្តាលស្តីពីការសម្របសម្រួល នៅមុនការវិភាគជាក្រុម

នៅក្នុងកិច្ចប្រជុំនេះសិក្ខាកាមមកពីអង្គការសង្គមស៊ីវិល ក៏មានឱកាសដើម្បីប្រើប្រាស់វិធីបណ្តុះបណ្តាលបែបច្នៃប្រឌិតផងដែរនៅក្នុងការបណ្តុះបណ្តាលនេះ ដែលរួមទាំងការកត់ត្រាបទបង្ហាញរបស់ពួកគេស្តីពីការសម្របសម្រួល និងទទួលបានយោបល់តបភ្លាមៗ ជាមួយអ្នកដទៃទៀតនៅក្នុងក្រុម ដើម្បីកែលម្អជំនាញរបស់ពួកគេ។

អង្គការសង្គមស៊ីវិល ដែលអ្នកខ្លះគឺជាអ្នកទទួលជំនួយខ្នាតតូចពីមូលនិធិ GREEN Mekong ក៏បានរាយការណ៍ផងដែរអំពីរបៀបដែលពួកគេប្រើប្រាស់ជំនាញថ្មីៗរបស់ខ្លួន ទាំងតាមរយៈជំនួយខ្នាតតូចរបស់ខ្លួន និងតាមរយៈប្រតិបត្តិការជា ធម្មតារបស់ពួកគេផងដែរ។

# បច្ចុប្បន្នភាពពីមូលនិធិ GREEN Mekong

មូលនិធិ GREEN Mekong (GMCF) បានបន្តបង្កើតលទ្ធផលប្រកបដោយជោគជ័យនៅទូទាំងតំបន់មេគង្គ ដែលរួមទាំង មីយ៉ាន់ម៉ា និងឡាវផងដែរ ដែលអ្នកទទួលមូលនិធិ GMCF ចំនួនពីរ ពោលគឺ អង្គការមូលនិធិអភិវឌ្ឍន៍មេត្តា (METTA) និងសមាគមជីវៈចម្រុះឡាវ (LBA) កំពុងធ្វើការយ៉ាងសកម្មនៅតាមមូលដ្ឋាន។ មូលនិធិ GMCF ត្រូវបានបង្កើតឡើង ដែលជាដំបូងសម្រាប់គាំទ្រដល់សិក្ខាកាមពីអង្គការសង្គមស៊ីវិល នៅក្នុងការអនុវត្តផែនការសកម្មភាព ដែលបានរៀបចំឡើងនៅក្នុងអំឡុងពេលនៃសិក្ខាសាលាប្រកាសការចាប់ផ្តើមវគ្គបណ្តុះបណ្តាលនេះ។ ចាប់តាំងពីពេលនោះមក មូលនិធិ នេះបានបង្ហាញពីសមត្ថភាពពេញលេញរបស់ខ្លួន ទាំងក្នុងការអនុញ្ញាតឲ្យមានភាពច្នៃប្រឌិត និងការវិវត្ត ក្នុងចំណោមអង្គការដែលជាអ្នកទទួលជំនួយ និងក្នុងការផ្តល់ឱកាសសម្រាប់អង្គការសង្គមស៊ីវិល ដើម្បីប្រើប្រាស់វគ្គបណ្តាលរបស់ពួកគេអំពីសមធម៌ផងដែរ។







បុគ្គលិកអង្គការមេត្តា បានធ្វើទស្សនកិច្ចតាមភូមិគោលដៅចំនួន ១០ និងបានជួបជាមួយមេដឹកនាំថ្នាក់ភូមិ និងសមាជិក MRMC ដើម្បីចែករំលែក និងជម្រុញសញ្ញាណព្រមទាំងដំណើរការនៃការគ្រប់គ្រងព្រៃកោងកាងដោយសមធម៌ផងដែរ។

ទោះបីគម្រោងរបស់អង្គការមេត្តា នឹងនៅបន្តរហូតដល់ខែសីហា ឆ្នាំ ២០១៥ក៏ដោយនៅក្នុងរយៈពេលបីខែដំបូង ពោលគឺ ខែមេសា ដល់ មិថុនា ឆ្នាំ ២០១៥ ការកសាងសមត្ថភាពរបស់ពួកគេអំពីសមធម៌ សម្រាប់អង្គការសហគមន៍ បានបង្កើតចេញជាលទ្ធផល រួចមកហើយ នៅក្នុងភូមិចំនួន ១០ និងផ្តល់ប្រយោជន៍ដល់ប្រជាជនចំនួន ១.៨២៦ គ្រួសារ។

ដោយសារតែការបាត់បង់ព្រៃឈើ កសិករដែលរស់នៅជិតព្រៃកោងកាងធម្មជាតិ បានរងការប៉ះពាល់ដោយផ្ទាល់ ជាងអ្នកដទៃទៀត ទោះបីនៅក្នុងពេលបច្ចុប្បន្ន ពួកគេក៏ជាអ្នកកាប់ដើមកោងកាងក៏ដោយ។ ពួកគេត្រូវចូលរួម និងរួមចំណែក នៅក្នុងយន្តការគ្រប់គ្រងធនធានព្រៃកោងកាងធម្មជាតិ។

សិក្ខាសាលាទាំងនេះ ត្រូវបានរៀបចំឡើង ដើម្បីពង្រឹងសមត្ថភាពរបស់អង្គការ សហគមន៍ និងគណៈកម្មការគ្រប់គ្រងធនធានព្រៃកោងកាង (MRMCs) ដើម្បីកែលម្អ ការដឹកនាំ និងការចាត់ចែងជំនាញ ចំណេះដឹងអំពីសមធម៌ អភិបាលកិច្ចល្អ និងការគ្រប់ គ្រង ដើម្បីធានាឲ្យមានការចូលរួមប្រកបដោយអត្ថន័យ ជាមួយសហគមន៍ដែលពឹងផ្អែកលើព្រៃកោងកាង។

បន្ថែមលើការកសាងសមត្ថភាពអំពីអភិបាលកិច្ចដោយសមធម៌ ដំណើរការរៀបចំសិក្ខាសាលារបស់អង្គការមេត្តា ក៏មានសមធម៌ផងដែរ ដោយបានសហការជិតស្និទ្ធជាមួយភូមិនានា ដើម្បីធានាឲ្យមានការគិតបញ្ចូលស្ត្រី និងអ្នកនេសាទតូចតាច ដែលពឹងផ្អែកតែលើព្រៃកោងកាងធម្មជាតិ។ ការធ្វើបែបនេះបាននាំឲ្យមានការយោគយល់គ្នាកាន់តែប្រសើរឡើងរវាងក្រុមអ្នកពាក់ព័ន្ធខុសៗគ្នានិងការយល់ដឹងអំពីមូលហេតុដែលថា ការចូលរួមនីមួយៗសុទ្ធតែមានសារៈសំខាន់។ លោក U Tin Kyay, Maung មកពីភូមិប៉ា បានកត់សំគាល់ថា“យើងចាំបាច់ត្រូវអភិរក្សព្រៃកោងកាងធម្មជាតិជាលក្ខណៈប្រព័ន្ធតាមរយៈការរួមចំណែករបស់សហគមន៍។ បើយើងមិនអភិរក្សព្រៃកោងកាងដែលមានស្រាប់ទេនោះ កសិករដែលរស់នៅជិតព្រៃកោងកាង នឹងរងការប៉ះពាល់កាន់តែធ្ងន់ធ្ងរបន្ថែមទៀត ជាងអ្នកដទៃ។”



ស្ត្រីជាមន្ត្រីព្រៃឈើថ្នាក់ខេត្តដែលចូលរួមនៅក្នុងវគ្គបណ្តុះបណ្តាលរបស់អង្គការ

នៅប្រទេសឡាវ ការងាររបស់អង្គការ LBA នៅក្រោមមូលនិធិ GMCF បានផ្តោតលើការចាត់ចែងវគ្គបណ្តុះបណ្តាលគ្រូបង្គោល។ គោលដៅចំបងរបស់ពួកគេគឺមន្ត្រីរដ្ឋាភិបាលមូលដ្ឋាន ដែលមានទំនាក់ទំនង និងដែលធ្វើការជិតស្និទ្ធជាមួយសហគមន៍នានានៅក្នុងការគ្រប់គ្រងធនធានព្រៃឈើនៅជុំវិញកន្លែងអភិរក្សភូតាសានក្នុងខេត្តផុងសាលី។ មន្ត្រីចំនួន ២០នាក់ មកពីការិយាល័យធនធានធម្មជាតិ និងបរិស្ថាននៅថ្នាក់ស្រុក និងការិយាល័យយុត្តិធម៌នៅថ្នាក់ស្រុក បានទទួលការបណ្តុះបណ្តាលអំពីសញ្ញាណ និងគោលការណ៍នានានៃសមធម៌ នៅក្នុងអភិបាលកិច្ចព្រៃឈើ និងអំពីរបៀបកែលម្អការចូលរួមធ្វើការជាមួយសហគមន៍មូលដ្ឋាន ដើម្បីបង្កើនការយល់ដឹងអំពីច្បាប់នានាដែលពាក់ព័ន្ធ និងពង្រឹងការសន្ទនា និងការផ្តល់យោបល់តបអំពីបញ្ហាព្រៃឈើនៅក្នុងមូលដ្ឋាន។

# ឯកសារនានាអំពីសមធម៌

## ក្រាហ្វិកព័ត៌មាន៖ ព្រៃឈើសង្គម និងការប្រែប្រួលអាកាសធាតុនៅអាស៊ាន




របាយការណ៍របស់ RECOFTC ស្ដីពី“ស្ថានភាពបច្ចុប្បន្ននៃព្រៃឈើសង្គមនៅក្នុងការបន្សាំ និងការកាត់បន្ថយការប្រែប្រួលអាកាសធាតុក្នុងតំបន់អាស៊ាន”ផ្ដល់ ជាគោល គំនិតអំពីទិន្នន័យវិស័យព្រៃឈើនៅថ្នាក់ជាតិ និងព័ត៌មានអំពីគម្របព្រៃឈើនិងកន្លែងនានាដែលគ្រប់គ្រងដោយពលរដ្ឋនៅក្នុងមូលដ្ឋានសម្រាប់ប្រទេសចំនួនប្រាំបីក្នុងអាស៊ាន (កម្ពុជា ឥណ្ឌូនេស៊ី ឡាវ ម៉ាឡេស៊ី មីយ៉ាន់ម៉ា ហ្វីលីពីន ថៃ និងវៀតណាម។ ក្រាហ្វិកព័ត៌មាននេះផ្ដល់ជាព័ត៌មានអំពីអ្វីដែលបង្ហាញក្នុងរបាយការណ៍នេះ។

មាននៅ៖ http://www.recoftc.org/project/asfcc/q-and/infographic-social-forestry-and-climate-change-asean

## ការអភិវឌ្ឍសមត្ថភាព៖ ការបង្ហាញខ្លួននៅក្នុងយុគសម័យអាកាសធាតុថ្មីមួយ ?



នៅខែមិថុនា ក្នុងកិច្ចប្រជុំ SBSTA 42 នៅទីក្រុងបោន ប្រទេសអាល្លឺម៉ង់លោកស្រី Regan Suzuki Pairojmahakij មកពីអង្គការ RECOFTC បានលើកឡើង ពីការកសាងសមត្ថភាពសម្រាប់សមធម៌ នៅក្នុងអភិបាលកិច្ចព្រៃឈើ និង ការពាក់ព័ន្ធសម្រាប់គោលនយោបាយ។ ដោយទទួលបានការលើកទឹកចិត្តភាគច្រើនពីបេកគំហើញ និងលទ្ធផលពីកម្មវិធី GREEN Mekong រហូតមកទល់បច្ចុប្បន្ននេះ លោកស្រីបានចាប់ផ្ដើមដោយពន្យល់ពីរបៀបដែលសមធម៌ មិនមែនជា”ដំណោះស្រាយសម្រាប់គ្រប់ករណីទាំងអស់ឡើយ” ប៉ុន្តែអាស្រ័យលើបរិបទ ភាសា អាទិភាព និងតម្រូវការចាំបាច់។ លោកស្រីបានបន្តបង្ហាញថា ដើម្បីឲ្យ REDD+ មាននិរន្តរភាព ការធានាឲ្យមានសមធម៌ មានសារៈសំខាន់បំផុត ហើយការកសាងសមត្ថភាពគឺជាយុទ្ធសាស្ត្រគន្លឹះមួយទើបអាចធ្វើការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុដោយសមធម៌ និងប្រសិទ្ធភាព។

ប្លក់ (Blog) របស់លោកស្រី Regan ដែលបង្ហោះព័ត៌មានអំពីសារៈសំខាន់នៃការអភិវឌ្ឍសមត្ថភាពសម្រាប់ការឆ្លើយតបដោយសមធម៌ ចំពោះការប្រែប្រួលអាកាសធាតុ http://bit.ly/1emgxdi

## ការបង្ហាញករណីអំពីសមធម៌៖ ការយល់ឃើញអំពីយុត្តិធម៌ ធៀបនឹងសមធម៌សង្គម នៅក្នុងប្រព័ន្ធបែងចែកផល ក្រោមកម្មវិធី REDD+

ការចែករម្លែកធនធានថ្មីៗស្ដីពីសមធម៌ គឺជាផ្នែកសំខាន់មួយនៃបេសកកម្មរបស់កម្មវិធី GREEN Mekong ដែលធ្វើឲ្យមានការយកចិត្តទុកដាក់ចំពោះផលិតផលចំណេះដឹងដែលបង្កើតជាមូលដ្ឋាននៃការងាររបស់កម្មវិធី GREEN Mekong។ ឯកសារនេះពិនិត្យមើលយន្តការនានាដែលអាចមាននៅក្នុងកម្មវិធីជាតិ REDD+ និងការពឹងផ្អែកលើថាតើ ការបាត់បង់ព្រៃឈើបច្ចុប្បន្ននេះ ភាគច្រើនកើតឡើងដោយសារអ្នកមាន ឬ ដោយសារសហគមន៍និងកសិករក្រីក្រ លទ្ធផលខុសៗគ្នា ដែលពាក់ព័ន្ធនឹងសមធម៌សង្គមនៅក្នុង REDD+។ ឯកសារនេះក៏បង្ហាញផងដែរថា យន្តការនានាដែលសិក្ខាកាមទំនងជាចាត់ទុកថាមានសមធម៌ មិនសុទ្ធតែដូចគ្នានឹងអ្វីដែលទំនងជាបង្កើនសមធម៌សង្គមឡើយ។

# ទស្សនៈយេនឌ័រ

## ករណីសិក្សានៅជុំវិញពិភពលោក បង្ហាញថា ការស្រាវជ្រាវបែបចូលរួមដែលឆ្លើយតបនឹងយេនឌ័រ គឺជាជម្រើសដែលគួរប្រកាន់យក

អ្នកស្រាវជ្រាវយេនឌ័រនៃអង្គការជីវៈជម្រុះអន្តរជាតិ ពិភាក្សាពីជោគជ័យរបស់ខ្លួននៅក្នុងការប្រើប្រាស់ឧបករណ៍ និងដំណើរការនៃការស្រាវជ្រាវតាមបែបចូលរួម នៅក្នុងគម្រោងស្រាវជ្រាវខុសៗគ្នា នៅប៊ូគីណាហ្វាសូ កាមេរូន ឥណ្ឌា និង ម៉ាឡេស៊ី។

សូមអានបន្ថែមនៅក្នុង៖ http://www.bioversityinternational.org/news/detail/case-studies-from-around-the-globe-show-that-gender-responsive-participatory-research-is-the-way-to-go/

## ការបញ្ជ្រាបយេនឌ័រទៅក្នុងគោលនយោបាយព្រៃឈើនៅអាស៊ី និងប៉ាស៊ីហ្វិក

របាយការណ៍នេះផ្ដោតលើរបៀបដែលទស្សនទានអំពីយេនឌ័រ ត្រូវបានដាក់បញ្ចូលទៅក្នុងគោលនយោបាយព្រៃឈើក្នុងប្រទេសចំនួនប្រាំបី នៅអាស៊ី-ប៉ាស៊ីហ្វិក (ប្រទេសនេប៉ាល់ ស្រីលង្កា កម្ពុជា ហ្វីជី ឥណ្ឌូនេស៊ី ហ្វីលីពីន ថៃ និងវៀតណាម)។ របាយការណ៍នេះ មានភ្ជាប់អនុសាសន៍គោលនយោបាយខ្លីៗដែលគូសបញ្ជាក់ពីការប្រឈមនានាសម្រាប់ស្ត្រី និងអនុសាសន៍នានាដើម្បីលើកកំពស់ការបញ្ជ្រាបយេនឌ័រនៅក្នុងវិស័យព្រៃឈើ។

ឯកសារនេះមាននៅក្នុង៖ http://www.recoftc.org/reports/mainstreaming-gender-forest-policies-asia-and-pacific


ព្រឹត្តិបត្រព័ត៌មាននេះ ចេញផ្សាយដោយ៖



**The GREEN Mekong program**
RECOFTC – The Center for People and Forests
P.O. Box 1111 Kasetsart Post Office Bangkok 10903, Thailand
green.mekong@recoftc.org
http://www.recoftc.org/project/green-mekong



រាល់ទស្សនៈដែលបានលើកឡើងនៅក្នុងឯកសារនេះ មិនឆ្លុះបញ្ចាំងអំពីទស្សនៈរបស់អង្គការរីខូហ្វ-មជ្ឈមណ្ឌលសម្រាប់មនុស្ស និងព្រៃឈើ (RECOFTC) និង USAID ឡើយ។ យើងមិនទទួលខុសត្រូវនូវរាល់កំហុសឆ្គង ឬ ការខ្វះចន្លោះនៅក្នុងការប្រែសម្រួលឯកសារនេះពីសំណៅដើមភាសាអង់គ្លេស ទៅជាភាសាដទៃទៀត។


យើងរីករាយនឹងទទួលយកនូវរាល់មតិយោបល់របស់លោកអ្នកចំពោះព្រឹត្តិបត្រព័ត៌មាននេះ ឬ ចូលរួមចំណែកមកក្នុងព្រឹត្តិបត្រព័ត៌មាននេះអំពីសមិទ្ធផល ឬ ការងាររបស់អ្នកអំពីសមធម៌។ សូមអ៊ីម៉ែលមកកាន់យើងខ្ញុំតាម៖ green.mekong@recoftc.org


កម្មវិធី GREEN Mekong បានទទួលមូលនិធិគាំទ្រពី USAID និងអនុវត្តដោយអង្គការរីខូហ្វ- មជ្ឈមណ្ឌលដើម្បីមនុស្ស និងព្រៃឈើ • ខែ កក្កដា ឆ្នាំ ២០១៥